# <u>សេចក្តីប្រកាសព័ត៌មាន</u>

## ការបើកសម្ពោធពិព័រណ៍រូបថតអនឡាញ «ទីកក់ក្តៅ» និង វីដេអូចម្រៀង «ពណ៌ស្នេហ៍»

នៅក្នុងឱកាសទិវាសិទ្ធិមនុស្សអន្តរជាតិឆ្នាំ២០២០នេះ អង្គការសហគមន៍ឥន្ទធនូកម្ពុជា(រ៉ក់) បានសម្ពោធពិព័រណ៍រូបថតក្រោមចំណងជើងថា «ទីកក់ក្តៅ» និង វីដេអូចម្រៀង «ពណ៌ស្នេហ៍» តាមរយៈប្រព័ន្ធអនឡាញរួមមាន បណ្តាញសង្គមហ្វេសប៊ុក ធ្វីតទ័រ និងគេហទំព័ររបស់រ៉ក់។ ទាំងរូបថត និង វីដេអូចម្រៀង គឺបង្ហាញពីសេចក្តីស្រឡាញ់របស់ក្រុមគ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា។ កម្មវិធីនេះបានចាប់ផ្តើមពីថ្ងៃទី០៤ ដល់ថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០២០ ក្នុងគោលបំណងអបអរសាទរនូវក្តីស្រឡាញ់ដែលចម្រុះ រាប់ទាំងវត្តមានរបស់គ្រួសារអ្នកស្រឡាញ់ភេទដូចគ្នា ឬគ្រួសារឥន្ទធនូនៅក្នុងប្រទេសកម្ពុជា ដែលបង្ហាញឱ្យឃើញថា ប្រទេសនេះគឺជាទីកក់ក្តៅសម្រាប់ប្រជាជនទាំងអស់ ហើយគ្រប់គ្នាបន្តជំរុញឱ្យសេចក្តីស្រឡាញ់កាន់តែ មានវិសាលភាពឡើងថែមទៀត។

ពិព័រណ៍រូបថតអនឡាញ «ទីកក់ក្តៅ[1]»បង្ហាញជូននូវកម្រងរូបថត និង សាច់រឿងសង្ខេប នៃអ្នកស្រឡាញ់ភេទដូចគ្នាចំនួន៧គ្រួសារ ដែលមានសណ្ឋានខុសៗគ្នា ដែលខ្លះជាក្រុមគ្រួសារសាច់ឈាមបង្កើត ហើយខ្លះទៀតជាគ្រួសារចិញ្ចឹម។ បើទោះបីជា ប្រទេសកម្ពុជាមិនទាន់មានច្បាប់ការអនុញ្ញាតិឱ្យដៃគូអ្នកស្រឡាញ់ភេទដូចគ្នារៀបអាពាហ៍ពិពាហ៍ និង សុំកូនពេញលេញបាននៅឡើយក៏ដោយ ក៏សេចក្តីស្រឡាញ់នៅតែជាខ្លឹមសារ ដ៏មានសារៈសំខាន់ក្នុងការកសាង និង ការរក្សាគ្រួសារ ដែលក្តីស្រឡាញ់នេះមានភាពស្មោះត្រង់ ការទទួលខុសត្រូវ ការចេះជជែកពិភាក្សា ការមើលថែរ ព្រមទាំងការយកចិត្តទុកដាក់ចំពោះគ្នា។ រូបថតទាំងនេះត្រូវបានថតដោយលោក ព្រហ្ម អ៊ីរ៉ូ សហការជាមួយ គម្រោងសិល្បៈស-ស និង គាំទ្រដោយអង្គការ Document Our History Now ។

ខាងក្រោមគឺជារូបថត និង សម្រង់សាច់រឿងមួយមានចំណងជើងថា «បំណងប្រាថ្នា ដើម្បីក្មេងជំនាន់ក្រោយ[2]»៖

តាថន៖«*នឹកឃើញគ្រានោះ យើងទាំងពីរស្ទើរតែបាត់បង់គ្នា ដោយសារតែឪពុកម្តាយបង្ខំផ្សំផ្គុំយាយឱ្យទៅប្រុសផ្សេង ហើយគ្រួសារគំរាមកំហែងដោយអាវុធ។ តែដោយចិត្តស្រឡាញ់ស្មោះ និង ជានិស្ស័យពិតប្រាកដ យើងអាចជំនះឧបសគ្គបានសព្វបែបយ៉ាង។ ខ្ញុំ និង យាយ កាន់តែចាស់ វាហួសពេលនឹងរៀបការហើយ។ តែពួកខ្ញុំខំប្រឹងចូលរួម*



[1] https://rockcambodia.org/km/warm-shelter-rainbow-families-photos-online-exhibition/

[2] https://rockcambodia.org/km/our-wishes-for-the-next-generation/

*ចែកបទពិសោធន៍ជីវិតគ្រួសារ ចង់ឱ្យសហគមន៍គាំទ្រ មានច្បាប់ទម្លាប់ការពារ ដើម្បីកូនចៅជំនាន់ក្រោយដែលស្រឡាញ់ភេទដូចគ្នា មានឱកាស មានសិទ្ធិរៀបការបំពេញបំណងខ្លួនឯងបាន ព្រោះវាក៏ជាសេចក្តីសុខមួយដែរ»។*

ចំណែកឯបទចម្រៀង «ពណ៌ស្នេហ៍[3]» ច្រៀងដោយសិល្បករវ័យក្មេងគឺ ឈីលី និង ហ៊ាង ក៏បានរួមបញ្ចូលក្តីស្រឡាញ់របស់មនុស្សចម្រុះគ្នា ដូចជាចំពោះខ្លួនឯង មិត្តភក្តិ គ្រួសារ និង អ្នកជាទីស្រឡាញ់ផងដែរ។ ក្តីស្រឡាញ់មានតម្លៃដូចៗគ្នា ដោយមិនប្រកាន់វណ្ណៈ អាយុ ភេទ យេនឌ័រ ជាតិសាសន៍ ពណ៌សម្បុរ ឡើយ។ អត្ថន័យខ្លឹមសារ ទាំងនេះបានឆ្លុះបញ្ចាំងក្នុងវីដេអូចម្រៀង តាមរយៈការចូលរួមសម្តែងដោយអ្នកស្ម័គ្រចិត្តដែលមានស្ថានភាពប្លែកៗពីគ្នា។

នៅក្នុងកំឡុងពេលនៃការរីករាលដាលជំងឺកូវីដ១៩ក្នុងសហគមន៍ជាលើកដំបូង គឺជាពេលដ៏លំបាកសម្រាប់ប្រជាជននៅក្នុងប្រទេសកម្ពុជា។ សហគមន៍ឥន្ទធនូកម្ពុជាសង្ឃឹមថា រូបថត សាច់រឿង និងចម្រៀងវីដេអូនៃសេចក្តីស្រឡាញ់ និង ទឹកកក់ក្តៅទាំងនេះ នាំមកនូវការជម្រុញលើកទឹកចិត្ត និងអារម្មណ៍ពោរពេញដោយ មនោសញ្ចេតនាដ៏ជ្រាលជ្រៅទៅកាន់សាធារណជនផងដែរ។ ទោះជាយ៉ាងណា ប្រជាពលរដ្ឋកម្ពុជានៅតែមានឱកាសប្រារព្ធសិទ្ធិមនុស្សរបស់ខ្លួន នាទិវាសិទ្ធិមនុស្សអន្តរជាតិសម្រាប់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២០ ដែលក្រុមងាយរងគ្រោះ ដូចជាសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នាក៏ចូលរួមបង្ហាញនូវ សម្លេងរបស់ខ្លួនផងដែរ។

###

សម្រាប់ព័ត៌មាន និងទំនាក់ទំនងទទួលរូបថត សូមទំនាក់នង៖

១. ទុយ រស្មី ៖ ជំនួយការផ្នែកទំនាក់ទំនង

លេខទូរស័ព្ទ ៖ 096 20 92 648/ 077 472 452

អ៊ីម៉ែល ៖ raksmey@rockcambodia.org

២. ហេង ជ័យលាភី ៖ អ្នកគ្រប់គ្រងក្រុមការងារកម្មវិធី

លេខទូរស័ព្ទ ៖ 012 78 00 60

អ៊ីម៉ែល ៖ leaphy@rockcambodia.org

បណ្តាញសង្គមរបស់រ៉ក់ ៖

គេហទំព័រ៖ www.rockcambodia.org

ហ្វេសប៊ុក៖ @rockhmerlgbt2009

ធ្វីតទ័រ៖ @rockcambodia

យូធ្យូប៖ https://www.youtube.com/channel/UCVgz-ms-xTUlbXsD16_CjoQ

---

[3] https://youtu.be/NWJBoi6vDVc